អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០១១

**សេចក្តីប្រកាសព័ត៌មាន**

**វេទិកាថ្នាក់តំបន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២**

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ ចំនួន **៣៥០** នាក់ មកពីតំបន់ភាគខាងត្បូងដែលរួមមានខេត្តកែប កំពត តាកែវ ព្រះសីហនុ និងខេត្តកោះកុង។ នេះជាវេទិកាលើកទី១សម្រាប់ឆ្នាំ២០១១ ដែលនឹងប្រព្រឹត្តិទៅនៅ **ថ្ងៃចន្ទ ទី១៧ ខែមករា ឆ្នាំ២០១១ នៅភោជនីយដ្ឋាន តាអ៊ី II ទីរួមខេត្តកំពត ចាប់ពីម៉ោង ៨:០០ ព្រឹក** ។

វេទិកាថ្នាក់តំបន់នេះមានបំណងលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីជួបជាមួយ ៖

-មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិដាក់ពាក្យបណ្តឹង ដំណើរការនៃការកាត់ក្តី និងជាពិសេសប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរៀបចំគម្រោងសំណងនិងស្នើទៅកាន់ អ.វ.ត.ក ។

-មន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍន៍ថ្មីៗរបស់តុលាការ។

-ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់សំណុំរឿង ០០២។

អង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក នឹងរៀបចំវេទិកាថ្នាក់តំបន់ចំនួនប្រាំទៀតនៅឆ្នាំ២០១១ នៅតំបន់ដទៃទៀត ក្នុងបំណងធ្វើយ៉ាងណាឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដែលមានចំនួនជាងពីរពាន់នាក់ បានចូលរួមគ្រប់ៗគ្នា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ឹម សុភា ប្រធានកម្មវិធីផ្សព្វផ្សាយតាមរយៈទូរស័ព្ទលេខ ០៧៧ ៧៧៧ ៣៦៧ ឬសារអេឡិកត្រូនិក im.sophea@eccc.gov.kh ។